ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចៀសវាង ការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (Double Taxation Agreement - DTA)




អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជាប្រថា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ នេះ មានរៀបចំពិធីចុះហត្ថលេខា លើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល (Double Taxation Agreement - DTA) រវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខាដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងរាជរដ្ឋាភិបាលកម្ពុជា និង ឯកឧត្តម **Don Pramudwinai** រដ្ឋមន្ត្រីក្រសួងការបរទេស នៃព្រះរាជាណាចក្រថៃ។

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងទី៤ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាជាមួយប្រទេសដៃគូ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងរដ្ឋាភិបាលនៃប្រទេសប្រ៊ុយណេ ដារូសាឡឹម ហើយត្រូវបានធ្វើឡើង ក្នុងបំណងផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជាហត្ថលេខី លើកិច្ចការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ធ្វើឱ្យប្រាកដប្រជាក្នុងការកំណត់សិទ្ធិយកពន្ធ បង្កើនមូលដ្ឋានគិតពន្ធ តាមរយៈការទាក់ទាញវិនិយោគដោយផ្ទាល់ លំហូរមូលធន ការផ្ទេរបច្ចេកវិទ្យា និងជំនាញពីបរទេស ការការពារនិវាសនជនពីប្រព្រឹត្តកម្មមិនត្រឹមត្រូវ ពាក់ព័ន្ធនឹងពន្ធ និងការការពារចំណូលពន្ធក្នុងស្រុក តាមរយៈកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំង នឹងការគេចវេះពន្ធរវាងប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅពេលដែលប្រទេសទាំងពីរផ្តល់សច្ចាប័នរួចរាល់តាមនីតិវិធីក្នុងស្រុករៀងៗខ្លួន។

កិច្ចព្រមព្រៀងនេះគឺជាសមិទ្ធផលថ្មីមួយទៀត ក្នុងចំណោមសមិទ្ធផលសំខាន់ៗជាច្រើន ដែលរាជរដ្ឋាភិបាល នីតិកាលទីប្រាំនៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រេចបាន ជាពិសេសក្នុងបរិបទ នៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន។ ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុង ធ្វើការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការគេចវេះបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ជាមួយបណ្តាប្រទេសអាស៊ាន និងអាស៊ីជាដៃគូមួយចំនួនទៀតដូចជា ម៉ាឡេស៊ី វៀតណាម កូរ៉េ ជាដើម៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ កិច្ចប្រជុំកាលពីថ្ងៃទី១៨-២២ ខែមករា ឆ្នាំ២០១៦


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ កិច្ចប្រជុំកាលពីថ្ងៃទី០២-០៤ ខែសីហា ឆ្នាំ២០១៧



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ កិច្ចប្រជុំកាលពីថ្ងៃទី១៨-២២ ខែមករា ឆ្នាំ២០១៦


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ កិច្ចប្រជុំកាលពីថ្ងៃទី០២-០៤ ខែសីហា ឆ្នាំ២០១៧